រដ្ឋសភា
ចូល
លេខ ៦១០៥
ថ្ងៃទី ០៧/០៥ ឆ្នាំ២០១៦ ម៉ោង ១០:៣០
បញ្ជូនទៅ

# ច្បាប់

# ស្តីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២.០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

### មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

### មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

### មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៤- អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សំដៅដល់អនីតិជន ដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- អ្នកទំនុកបម្រុង សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន សំដៅដល់របាយការណ៍ស្តីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្តល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- មណ្ឌលយុវនីតិសម្បទា សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២

## គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

### មាត្រា ៥.- គោលការណ៍ជាមូលដ្ឋាន

គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវជានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណាពល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេស ជានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្ដីថ្លៃថ្នូរទៅលើអនីតិជន
- ត្រូវផ្ដល់ឱកាសឲ្យអនីតិជនសម្ដែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត
- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀតដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក តាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អនីតិជន និងដែលនាំឲ្យបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្ដីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជ-អាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ
- សន្មតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។